ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

# ចំណាប់អារម្មណ៍

## ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាល សម្រាប់ទ្រទ្រង់ដំណើរការអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) ក្នុងពិធីប្រកាសសាលក្រម របស់អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក. សំណុំរឿង០០២ ដំណាក់កាលទី២ ប្រឆាំងនឹង នួន ជា និង ខៀវ សំផន

ថ្ងៃនេះ ដែលជាថ្ងៃប្រកាសសាលក្រមនៃសំណុំរឿង០០២ ដំណាក់កាលទី២ គឺជាថ្ងៃប្រវត្តិសាស្ត្រមួយទៀត សម្រាប់ប្រជាជនកម្ពុជាយើង និងសម្រាប់មនុស្សជាតិទាំងមូល ពាក់ព័ន្ធនឹងដំណើរការស្វែងរកយុត្តិធម៌នៅក្នុងក្របខ័ណ្ឌនៃឧក្រិដ្ឋកម្មព្រហ្មទណ្ឌជាតិ និងអន្តរជាតិ។ នៅក្នុងរយៈកាលជិតបួនទសវត្សរ៍ ចាប់តាំងពីរបបកម្ពុជាប្រជាធិបតេយ្យហៅកាត់ថា «របបខ្មែរក្រហម» ត្រូវបានផ្តួលរំលំនៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ មក កម្ពុជាយើង មិនដែលមានការស្ទាក់ស្ទើរក្នុងការស្វែងរកយុត្តិធម៌ម្តងណាឡើយ ដើម្បីបញ្ចប់និទណ្ឌភាពចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅក្នុងរបប ៣ឆ្នាំ ៨ខែ និង២០ថ្ងៃ ដែលធ្វើឱ្យប្រជាជនរបស់យើងរាប់លាននាក់បានបាត់បង់ជីវិត។

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃបំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក.) ដោយបានអញ្ជើញអង្គការសហប្រជាជាតិ ឱ្យចូលរួមជាមួយយើងនៅក្នុងតុលាការជាតិ ដែលមានចរិកលក្ខណៈជាអន្តរជាតិ និងមានការចូលរួមពីសហគមន៍អន្តរជាតិ គឺជាកិច្ចខិតខំប្រឹងប្រែងមួយមិនធ្លាប់មានពីមុន។ គោលបំណងរបស់យើង គឺដើម្បីស្វែងរកយុត្តិធម៌ក្នុងក្របខ័ណ្ឌសន្តិភាព ស្ថេរភាពនយោបាយ និងបង្រួបបង្រួមជាតិ ដែលជាមធ្យោបាយដ៏សំខាន់មួយក្នុងការគោរព និងការចងចាំដល់ជនរងគ្រោះទាំងអស់ ដើម្បីជួយពង្រឹងនីតិរដ្ឋនៅក្នុងប្រទេសរបស់យើង និងដើម្បីធានាកុំឲ្យមានសោកនាដកម្មបែបនេះកើតឡើងសាជាថ្មីនៅទីនេះ ឬនៅទីណាៗទាំងអស់នៅក្នុងពិភពលោកនេះ។

ហេតុមកទល់ពេលនេះ អ.វ.ត.ក. បានបញ្ចប់ជាស្ថាពរនូវសំណុំរឿងចំនួនបី រួមមាន៖ ទី១-សំណុំរឿង ០០១ ចំពោះពិរុទ្ធជន កាំង ហ្គិកអ៊ាវ ហៅឌុច ដែលបាន និងកំពុងអនុវត្តទោសអស់មួយជីវិតនៅពន្ធនាគារ ទី២- សំណុំរឿង ០០២ ដំណាក់កាលទី១ ចំពោះជនជាប់ចោទ នួន ជា និងខៀវ សំផន ដែលត្រូវបានអង្គជំនុំជម្រះតុលាការផ្តន្ទាទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិត កាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦កន្លងមកនេះ និងទី៣-សំណុំរឿង០០៤/១ ចំពោះជនសង្ស័យ អ៊ឹម ចែម ដែលត្រូវបានលើកលែងការចោទប្រកាន់ កាលពីខែមិថុនា ឆ្នាំ២០១៨កន្លងមកនេះ។

ចំពោះសំណុំរឿង០០២ ដំណាក់កាលទី២ អង្គជំនុំជម្រះសាលាដំបូង បានធ្វើសវនាការរយៈពេលសរុប ចំនួន ២៨៣ថ្ងៃ លើភស្តុតាងពាក់ព័ន្ធនឹងបទចោទប្រកាន់ស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ប្រឆាំងនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន។ ក្នុងអំឡុងពេលសវនាការនេះ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មពីបុគ្គលសរុបចំនួន ១៨៥ នាក់ ក្នុងនោះ មានសាក្សីបញ្ជាក់អង្គហេតុចំនួន ១១៤ នាក់ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦៣ នាក់ និងអ្នកជំនាញចំនួន ៨ នាក់។ សវនាការនេះ មានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសាធារណជន ដោយមានសាធារណជនចូលរួមស្តាប់ និងតាមដានសវនាការនេះដោយផ្ទាល់សរុបចំនួន ៨២ ៧៨០ នាក់។ សំណុំរឿង០០២ ត្រូវគេចាត់ទុកថាជា «សំណុំរឿងសំខាន់ជាងគេបង្អស់នៅក្នុងសាវតានៃប្រព័ន្ធយុត្តិធម៌អន្តរជាតិ ចាប់តាំងពីការជំនុំជម្រះក្តីនៅនូរិមប៊ើក (Nuremberg) ប្រទេសអាល្លឺម៉ង់» ដោយហេតុថា សាលាក្តីបានចោទប្រកាន់មេដឹកនាំជាន់ខ្ពស់របបកម្ពុជាប្រជាធិបតេយ្យ ដែលនៅមានជីវិតចំនួនបួនរូបតែម្តង។ គួរឱ្យសោកស្តាយ ជនជាប់ចោទចំនួន២នាក់ គឺលោក អៀង សារី និងលោកស្រី អៀង ធីរិទ្ធ មិនបានរស់នៅដើម្បីប្រឈមមុខជាមួយតុលាការទេ ខណៈដែលជនរងគ្រោះជាច្រើនទៀត ក៏បានលាចាកលោកដោយពុំបានឃើញយុត្តិធម៌សម្រាប់ពួកគេនៅឡើយ។

ជាមួយគ្នានេះដែរ ក្រៅពីទិដ្ឋភាពយុត្តាធិការ អ.វ.ត.ក. ក៏សម្រេចបាននូវសមិទ្ធិផលមិនមែនផ្នែកតុលាការមួយចំនួនទៀត រួមមាន៖

ទី១.កេរដំណែល(Legacy) របស់ អ.វ.ត.ក ត្រូវបានចាត់ទុកជាកត្តាដ៏សំខាន់បំផុតដែលគួរថែរក្សាទុក និងផ្តល់ទុកឱ្យសម្រាប់មនុស្សជំនាន់ក្រោយ ដែលរួមមាន៖ ការចងចាំ និងការទប់ស្កាត់របបប្រល័យពូជសាសន៍(Remembrance and Non-Recurrence) និងការអប់រំ ក៏ដូចជាការកសាងសមត្ថភាព និងការពង្រឹងស្ថាប័ន ក្នុងវិស័យយុត្តិធម៌។ នាពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានកំណត់យកថ្ងៃទី២០ ឧសភា ជារៀងរាល់ឆ្នាំ ជា «***ទិវាជាតិនៃការចងចាំ***» និងជាថ្ងៃឈប់សម្រាកសាធារណៈ។

ទី២.អ.វ.ត.ក ត្រូវបានទទួលស្គាល់ជាអន្តរជាតិថាជាតុលាការកូនកាត់គំរូមួយ សម្រាប់ធ្វើការវិនិច្ឆ័យនូវឧក្រិដ្ឋកម្ម និងការសម្លាប់រង្គាល។ ប្រទេសខ្លះ កំពុងស្ថិតក្នុងដំណាក់កាលគិតគូរ និង

ប្រទេសខ្លះទៀត បាន និងកំពុងបង្កើតជាបណ្តើរៗ ដូចជាបង់ក្លាដេស ស្រីលង្កការ កេនយ៉ា សេណេកាល់ និងអាហ្វ្រិកកណ្តាល ជាដើម។

ទី៣.ជនរងគ្រោះប្រមាណ៤០០០នាក់ ត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី (Civil Parties) នៅក្នុងសំណុំរឿង០០២ ហើយក៏ត្រូវបានអនុញ្ញាតឱ្យចូលរួមដោយផ្ទាល់នៅក្នុងដំណើរការជម្រះក្តី ព្រមទាំងមានសិទ្ធិទាមទារសំណងផ្លូវចិត្ត និងជាសមូហភាព (Moral and Collective Reparations)។ ត្រង់ចំណុចនេះ អ.វ.ត.ក បានផ្តល់ជាគំរូមួយ និងក្លាយជាជំហាននាំមុខដ៏សំខាន់ជាងគេ បើប្រៀបធៀបទៅនឹងតុលាការ ព្រហ្មទណ្ឌអន្តរជាតិដ៏ទៃទៀត។

ទី៤.សាធារណជនកម្ពុជាជាងកន្លះលាននាក់ បានមកឃើញដំណើរការស្វែងរកយុត្តិធម៌នៅ អ.វ.ត.ក ដោយផ្ទាល់ ឬតាមរយៈសកម្មភាពផ្សព្វផ្សាយ(Outreach Activities) ដែលរៀបចំដោយផ្នែកកិច្ចការសាធារណៈ អង្គភាពគាំពារជនរងគ្រោះ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

ទី៥.មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ (ម.ត.ឯ.ច) ពាក់ព័ន្ធនឹង អ.វ.ត.ក. ត្រូវបានបានបង្កើតឡើងតាំងពីចុងឆ្នាំ២០១៥ ដែលមានតួនាទីតម្កល់ឯកសារច្បាប់ និងឯកសារពាក់ព័ន្ធស្តីពីដំណើរការជំនុំជម្រះក្តីរបស់អ.វ.ត.ក. សម្រាប់ឱ្យសាធារណជន អ្នកស្រាវជ្រាវជាតិ និងអន្តរ-ជាតិ មកសិក្សាស្វែងយល់។

ទី៦.ប្រវត្តិសាស្ត្រស្តីពីរបបខ្មែរក្រហម ត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សាថ្នាក់ទី១២ កម្រិតវិទ្យាល័យ សម្រាប់ឱ្យសិស្ស និងយុវជនជំនាន់ក្រោយធ្វើការសិក្សាស្វែងយល់អំពីប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតរបស់ខ្លួន។

ទី៧.ទស្សនទានស្តីពីរដ្ឋបាលតុលាការ ដែលយកគំរូតាម អ.វ.ត.ក ត្រូវបានបង្កើតឡើង និងបញ្ចូលទៅក្នុងច្បាប់អង្គការទាំងបីនៃប្រព័ន្ធយុត្តិធម៌ និងត្រូវបានដាក់ឱ្យអនុវត្តនៅប្រព័ន្ធតុលាការជាតិ។ បច្ចុប្បន្ននេះ តុលាការជាតិគ្រប់លំដាប់ថ្នាក់មានអង្គភាពអចិន្ត្រៃយ៍មួយ ហៅថា «រដ្ឋបាលតុលាការ»ដើម្បីធ្វើឱ្យសេវាសាធារណៈផ្នែកយុត្តិធម៌កាន់តែមានប្រសិទ្ធិភាពដល់អ្នកប្រើប្រាស់។

ទោះបីជាដំណើរការកាត់សេចក្តីរបស់អ.វ.ត.ក. បានប្រព្រឹត្តទៅយូរជាងការរំពឹងទុក និងរហូតមកទល់ពេលនេះ បានចំណាយថវិកាអស់ប្រមាណ ២៩៧ លានដុល្លារអាមេរិក ដែលទទួលបានពីរាជ-រដ្ឋាភិបាលកម្ពុជា និងពីបណ្តាប្រទេសផ្តល់ជំនួយជាង៣៥ប្រទេសទៀតផងក៏ដោយ ក៏គ្រប់ភាគីពាក់ព័ន្ធទាំងអស់ រួមមានៈ រាជរដ្ឋាភិបាលកម្ពុជា អង្គការសហប្រជាតិ និងបណ្តាប្រទេសផ្តល់ជំនួយទាំងអស់ បានសំដែងទស្សនៈដូចគ្នាថា «អ.វ.ត.ក. បាន និងកំពុងសម្រេចបាននូវសមិទ្ធផលទាំងផ្នែកយុត្តា-ធិការ និងមិនមែនផ្នែកយុត្តាធិការយ៉ាងច្រើន»។ ជាងនេះទៅទៀត អ.វ.ត.ក. ក៏បាន និងកំពុងបន្សល់ទុកកេរដំណែលដ៏ល្អនៅក្នុងសង្គមកម្ពុជា ហើយក៏បានផ្ទេរចំណេះដឹង និងបទពិសោធពី អ.វ.ត.ក ទៅតុលាការជាតិ និងស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធផ្សេងទៀតផងដែរ ព្រមទាំងបង្កើតបានជាយុត្តិសាស្ត្រមួយចំនួន (Jurisprudences) សម្រាប់រួមចំណែកទៅក្នុងប្រព័ន្ធយុត្តិធម៌អន្តរជាតិ។ ក្នុងរយៈពេលប្រាំឆ្នាំ

ចុងក្រោយនេះ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើនវិភាគទានថវិកាជាលំដាប់ដល់ អ.វ.ត.ក និងបានផ្តល់ថវិកាសម្រាប់បើកប្រាក់បៀវត្សជូនបុគ្គលិកជាតិយ៉ាងតិចចំនួន ៦ ខែរៀងរាល់ឆ្នាំ បន្ថែមទៅនឹងការទទួលរ៉ាប់រងចំណាយ១០០% ទៅលើចំណាយប្រតិបត្តិការរបស់តុលាការ ចាប់តាំងពីការបង្កើត អ.វ.ត.ក. នៅឆ្នាំ២០០៦មក។ រហូតមកទល់ពេលនេះ រាជរដ្ឋាភិបាលកម្ពុជា បានរួមចំណែកជាថវិកាបដិភាគ និងជាសម្ភារដល់ អ.វ.ត.ក. ដែលមានទឹកប្រាក់សរុប ៤៦,៨ លានដុល្លារអាមេរិក ដែលជាប់ចំណាត់ថ្នាក់ទី២ បន្ទាប់ពីប្រទេសជប៉ុន (ចំនួន៨៥,៨លានដុល្លារអាមេរិក)។

ខ្ញុំសូមឆ្លៀតយកឱកាសនេះ សម្តែងនូវការកោតសរសើរយ៉ាងជ្រាលជ្រៅជូនចំពោះអ្នកទាំងឡាយដែលបានចូលរួមចំណែកនៅក្នុងដំណើរការនេះ រួមមាន ចៅក្រម ព្រះរាជអាជ្ញា មេធាវី មន្ត្រីច្បាប់ និងបុគ្គលិកតុលាការទាំងអស់ គឺទាំងខាងភាគីជាតិ និងអន្តរជាតិ ព្រមទាំងប្រជាជន និងបណ្តារដ្ឋាភិបាលនានាដែលបានផ្តល់ថវិកា ពោលគឺមិត្តរបស់សាលាក្តី។ ខ្ញុំក៏សូមថ្លែងអំណរគុណ និងកោត-សរសើរដល់ អ.ស.ប ដែលបានខ្នះខ្នែងជួយក្នុងដំណើរការសាលាក្តីខ្មែរក្រហម តាំងពីការកសាងច្បាប់រហូតដល់ពេលនេះ ដោយបានបញ្ជូនបេសកជនសំខាន់ៗមកពិភាក្សាជាមួយរាជរដ្ឋាភិបាលកម្ពុជា។ សក្ខីកម្មជាក់ស្តែង នៅពេលប្រកាសសាលក្រមលើសំណុំរឿង០០២ ដំណាក់កាលទី២នេះ ឯកឧត្តម អគ្គលេខាធិការ អង្គការសហប្រជាជាតិ បានបញ្ជូនឯកឧត្តម អគ្គលេខាធិការរង Miguel de Serpa Soares អ្នកជំនាញការច្បាប់ដ៏ចំណានមកចូលរួមស្តាប់ ដែលញ៉ាំងឱ្យការប្រកាសសាលក្រមនាពេលនេះកាន់តែអធិកអធមក្រៃលែង។ ជាពិសេស ខ្ញុំក៏សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណា-ចក្រកម្ពុជា ដែលតែងតែយកចិត្តទុកដាក់គាំទ្រដល់រាល់ដំណើរការទាំងឡាយរបស់សាលាក្តី ចាប់តាំងពីគំនិតផ្តួចផ្តើមក្នុងការបង្កើតតុលាការ និងបន្តគាំទ្រទាំងផ្នែក ថវិកា និងសម្ភារដល់ អ.វ.ត.ក. ក្នុងបុព្វហេតុនៃការចងចាំប្រវត្តិសាស្ត្រ ក៏ដូចជាចូលរួមពង្រឹង និងថែរក្សាសន្តិភាព ការបង្រួបបង្រួមជាតិ ការផ្សះផ្សាជាតិ និងការអភិវឌ្ឍសង្គមកម្ពុជាឱ្យបានរឹងមាំ និងស្ថិតស្ថេរជាយូរអង្វែង សម្រាប់មនុស្សរាប់ជំនាន់ទៅមុខទៀត។

ជាទីបញ្ចប់ ខ្ញុំសូមជម្រាបជូនដល់អ្នកដែលរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យថា៖ ថ្ងៃនេះ ប្រជាជនកម្ពុជា និងពិភពលោកទាំងមូល សូមរំឭកចងចាំដល់អ្នកដែលបានចែកឋានទៅ ព្រមទាំងអ្នកដែលរងគ្រោះ ដោយសារឧក្រិដ្ឋកម្មនៃរបបនោះ។ យើងសង្ឃឹមថាការជំនុំជម្រះក្តី និងការចេញសាលក្រមនៃសំណុំរឿង ០០២ ដំណាក់កាលទី២នាពេលនេះ ពិតជាអាចរំលែកការឈឺចាប់ និងទុក្ខវេទនារបស់អស់លោក លោកស្រីបានខ្លះដាក់ជាពុំខាន៕

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨